ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ... សហវ ...

ថ្ងៃ ... ខែ កត្តិក ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២៤

**ជម្រាបជូន**
**ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ៖** ករណីការស្នើសុំពង្រីកវិសាលភាពអនុវត្តការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំកម្រិតកម្មវិធី។

**យោង៖** -លិខិតលេខ ៣៥/២៤ គទក ល.ស ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០២៤ របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

-លិខិតលេខ ៤៨៩៣ សហវ.អថ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យនិងសម្រេចជាគោលការណ៍ដូចខាងក្រោម៖

១)- **គោលការណ៍ឧបត្ថម្ភ**

អនុញ្ញាតផ្តល់ជាប្រាក់ឧបត្ថម្ភជូនគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា សម្រាប់ចុះវាយតម្លៃគុណភាពអប់រំកម្រិតឧត្តមសិក្សា តាមនិយាមដូចខាងក្រោម៖

❖ **សម្រាប់កម្រិតឧត្តមសិក្សា**

- <u>ប្រាក់ឧបត្ថម្ភសេវាចុះវាយតម្លៃនៅរាជធានីភ្នំពេញ</u>៖
  - ផ្តល់ជូនទឹកប្រាក់យ៉ាងច្រើនចំនួន ២០ ៤០០ ០០០ រៀល សម្រាប់ការចុះវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំ ក្នុងមួយគ្រឹះស្ថានឧត្តមសិក្សា។
  - ផ្តល់ជូនទឹកប្រាក់យ៉ាងច្រើនចំនួន ៥ ២០០ ០០០ រៀល សម្រាប់ការចុះវាយតម្លៃពាក់កណ្តាលអាណត្តិ ក្នុងមួយគ្រឹះស្ថានឧត្តមសិក្សា។
- <u>ប្រាក់ឧបត្ថម្ភសេវាចុះវាយតម្លៃនៅតាមបណ្តាខេត្ត</u>៖
  - ផ្តល់ជូនទឹកប្រាក់យ៉ាងច្រើនចំនួន ៣៤ ៤០០ ០០០ រៀល សម្រាប់ការចុះវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំ ក្នុងមួយគ្រឹះស្ថានឧត្តមសិក្សា។
  - ផ្តល់ជូនទឹកប្រាក់យ៉ាងច្រើនចំនួន ៨ ៧០០ ០០០ រៀល សម្រាប់ការចុះវាយតម្លៃពាក់កណ្តាលអាណត្តិ ក្នុងមួយគ្រឹះស្ថានឧត្តមសិក្សា។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

❖ **សម្រាប់កម្រិតកម្មវិធី**

- **ប្រាក់ឧបត្ថម្ភសេវាចុះវាយតម្លៃនៅរាជធានីភ្នំពេញ៖**
  - ផ្តល់ជូនទឹកប្រាក់យ៉ាងច្រើនចំនួន ៧ ២៨០ ០០០ រៀល សម្រាប់ការចុះវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំ ក្នុងមួយកម្មវិធី របស់គ្រឹះស្ថានឧត្តមសិក្សា។
  - ផ្តល់ជូនទឹកប្រាក់យ៉ាងច្រើនចំនួន ២ ៥៦០ ០០០ រៀល សម្រាប់ការចុះវាយតម្លៃពាក់កណ្តាលអាណត្តិ ក្នុងមួយកម្មវិធី របស់គ្រឹះស្ថានឧត្តមសិក្សា។
- **ប្រាក់ឧបត្ថម្ភសេវាចុះវាយតម្លៃនៅតាមបណ្តាខេត្ត៖**
  - ផ្តល់ជូនទឹកប្រាក់យ៉ាងច្រើនចំនួន ១២ ១៨០ ០០០ រៀល សម្រាប់ការចុះវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំ ក្នុងមួយកម្មវិធី របស់គ្រឹះស្ថានឧត្តមសិក្សា។
  - ផ្តល់ជូនទឹកប្រាក់យ៉ាងច្រើនចំនួន ៤ ២៤០ ០០០ រៀល សម្រាប់ការចុះវាយតម្លៃពាក់កណ្តាលអាណត្តិ ក្នុងមួយកម្មវិធី របស់គ្រឹះស្ថានឧត្តមសិក្សា។

## ២)- មុខសញ្ញាចំណាយ

មុខសញ្ញាចំណាយខាងក្រោមនេះត្រូវបានអនុញ្ញាតនៅក្នុងកញ្ចប់ថវិកាដែលត្រូវផ្តល់ជូន៖

- ប្រាក់ហោប៉ៅរបស់មន្ត្រីវាយតម្លៃ
- សោហ៊ុយហូបចុក ស្នាក់នៅ និងសោហ៊ុយធ្វើដំណើររបស់មន្ត្រីវាយតម្លៃ
- ចំណាយរដ្ឋបាលផ្សេងៗ។

## ៣)- នីតិវិធីចំណាយ និងកិច្ចបញ្ជិកា

- ក្រសួងអប់រំ យុវជន និងកីឡា (គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា) ត្រូវស្នើសុំការចំណាយ តែក្នុងរង្វង់ឥណទានថវិកាដែលបានគ្រោងទុកក្នុងផែនការឥណទានថវិកាប្រចាំឆ្នាំរបស់ខ្លួន។
- ដើម្បីអនុវត្តសកម្មភាពចុះវាយតម្លៃបានទាន់ពេលវេលា ក្រសួងអប់រំ យុវជន និងកីឡា (គណៈកម្មការធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា) ត្រូវអនុវត្តតាមនីតិវិធីចំណាយព្រម ពោលគឺត្រូវរៀបចំគម្រោងអំពីចំនួនគ្រឹះស្ថានឧត្តមសិក្សានិងចំនួនកម្មវិធីដែលត្រូវចុះវាយតម្លៃ ព្រមទាំងគម្រោងចំណាយថវិកាស្របតាមគោល-ការណ៍របបឧបត្ថម្ភ រួចបោះផ្សាយអាណត្តិព្រមតែម្តង និងស្នើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច។
- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវគ្រោងឥណទានថវិកាសម្រាប់មុខសញ្ញាចំណាយនេះ ចូលក្នុងអនុគណនី ៦១៩៨១ (សេវាកម្មផ្សេងៗទៀត)

- ឯកសារសេក្តីបត្រចំណាយ និងឯកសារយុត្តិកម្មផ្សេងៗលើការចំណាយនេះ ត្រូវរក្សាទុកនៅអង្គភាពដើម ដើម្បីជាកម្មវត្ថុនៃសវនកម្មក្រោយចំណាយរបស់ស្ថាប័នមានសមត្ថកិច្ច ។

៤)- **និរាករណ៍**

លិខិតលេខ ៤៨៩៣ សហវ.អថ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទុកជានិរាករណ៍។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ជ្រាប និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ទទួលនូវគោរវកិច្ចពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន